## ១៣ សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «បឋមមន្ត្រីពន្ធនាគារ»

### ក- រូបសញ្ញា




### ខ- សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «បឋមមន្ត្រីពន្ធនាគារ»

មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**ខ.១- ទម្រង់**

- មានរាងជារង្វង់មូល ដែលផ្នែកខាងលើក្នុងរង្វង់ មានផ្ទៃពណ៌ក្រហម ដោយសរសេរឈ្មោះក្រសួង រាងកោង «**ក្រសួងមហាផ្ទៃ**» ពណ៌មាស។
- ផ្នែកខាងក្នុងរង្វង់ មានឆ្នូតបីពណ៌មាសកាត់ទទឹងនិងឆ្នូតបីបណ្ដោយរង្វង់ នៅចំណុចពាក់កណ្ដាល នៃរង្វង់ទាំងសងខាង។ រីឯនៅខាងក្នុងផ្នែកខាងលើ មានសរសេរឈ្មោះក្រសួងរាងកោងជាភាសាអង់គ្លេស **“MINISTRY OF INTERIOR”**
- នៅចំកណ្ដាល មានរូបព្រះគណេសពាក់កណ្ដាលខ្លួន ពណ៌មាស ឯផ្ទៃខាងក្រោយពណ៌លឿងខ្ចី ហើយខាងក្រោម មានផ្កាចន្ទន៍ចំនួន៧ ដែលតំណាងឱ្យសាលានគរបាលជាតិទាំង៧ នៅតាមបណ្ដាខេត្តនៃប្រទេសកម្ពុជា។
- នៅខាងក្រោមផ្កាចន្ទន៍ មានសរសេរឈ្មោះបណ្ឌិត្យសភារាងកោងជាភាសាអង់គ្លេស **“POLICE ACADEMY OF CAMBODIA”**

រីឯនៅខាងក្នុងផ្ទៃកខាងក្រោម មានបូក្រហម មានសរសេរឈ្មោះបណ្ឌិត្យសភាជាភាសាខ្មែររាងកោង **«បណ្ឌិត្យសភានគរបាលកម្ពុជា»** ពណ៌ស។
- ផ្ទៃកខាងក្រោមក្នុងរង្វង់ មានផ្ទៃពណ៌ផ្ទៃមេឃ ដោយសរសេរឈ្មោះវគ្គរាងកោង **«បឋមមន្ត្រីពន្ធនាគារ»** ពណ៌ប្រាក់។

**ខ.២- អត្ថន័យ**

- **រង្វង់មូល មានរឹមពន្ធជុំវិញពណ៌មាស** តំណាងឱ្យភាពរឹងមាំ អត់ធ្មត់របស់មន្ត្រីពន្ធនាគារ ក្នុងការចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គមជូនប្រជាពលរដ្ឋទូទៅ។
- **ព្រះគណេស** ជាអាទិទេពតំណាងឱ្យច្បាប់ បញ្ញា ចំណេះដឹង និងជាអាទិទេពនៃការបំផ្លាញឧបសគ្គ និងអំពើអាក្រក់ទាំងឡាយ។ ក្នុងន័យនេះ ព្រះគណេសតំណាងឱ្យភាពជាអ្នកប្រាជ្ញ ជាបណ្ឌិត ជាអ្នកចេះដឹង អ្នកជួយដល់សត្វទាំងឡាយគ្រប់ទីកន្លែង ដោយប្រកាន់ខ្ជាប់នូវអំពើល្អ សុចរិតភាព ភាពម៉ឺងម៉ាត់ និងហ្មត់ចត់ព្រមទាំងបង្កើតឱ្យមានភាពសម្បូររុងរឿង វឌ្ឍនភាព និងវិបុលភាព។
- **បូមានពណ៌ផ្ទៃមេឃ** រំលេចវគ្គសិក្សា **«បឋមមន្ត្រីពន្ធនាគារ»** ពណ៌ប្រាក់ តំណាងឱ្យភាពម៉ត់ចត់ ម៉ឺងម៉ាត់ របស់មន្ត្រីពន្ធនាគារក្នុងការប្រតិបត្តិការងារនៅគ្រប់ពេលវេលា។
- **បូមានពណ៌ក្រហម** តំណាងឱ្យភាពអង់អាចនិងកម្លាំងអនុភាពរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការជំរុញឱ្យអង្គភាពចំណុះនិងអ្នកសិក្សាបំពេញបានតាមស្តង់ដាគុណភាព ដែលបានកំណត់។
- **អក្សរពណ៌មាស** តំណាងឱ្យពន្លឺនៃវិជ្ជាអប់រំបញ្ញា ប្រាជ្ញាស្មារតី ភាពឧត្តុង្គឧត្តមសេចក្តីថ្លៃថ្នូរ គុណតម្លៃ និងភាពរឹងមាំរបស់មន្ត្រីពន្ធនាគារ។
- **អក្សរពណ៌ប្រាក់** តំណាងឱ្យភាពវៃឆ្លាត ចេះបត់បែន និងសម្របសម្រួលការងារទូទៅរបស់មន្ត្រី។
- **អក្សរពណ៌ស** **«បណ្ឌិត្យសភានគរបាលកម្ពុជា»** តំណាងឱ្យភាពបរិសុទ្ធ ស្លូតបូត និងមិនលម្អៀងដោយអគតិទាំង៤ក្នុងការបណ្តុះបណ្តាល។
- ពាក្យ **«បឋមមន្ត្រីពន្ធនាគារ»** ជាឈ្មោះនៃវគ្គបណ្តុះបណ្តាល ដែលបណ្ឌិត្យសភាធ្វើការបណ្តុះបណ្តាលដល់សិក្ខាកាមដែលជាមន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ ដែលមិនទាន់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលពីមុន។
- រូបរាងសញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ **«បឋមមន្ត្រីពន្ធនាគារ»** ដូចមានភ្ជាប់ក្នុងសេចក្តីពន្យល់នេះ។
- សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ **«បឋមមន្ត្រីពន្ធនាគារ»** ត្រូវបានប្រើប្រាស់ដោយបំពាក់ជាប់គម្របហោប៉ៅអាវឬបំពាក់ពីលើហោប៉ៅអាវផ្នែកខាងស្តាំ។